# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាអគ្គសញ្ញាលាបថ្ងាសនៅទួលតាំង
# ថ្ងៃទី០៤ មេសា ២០១៧

អត្ថបទទី១៖ ជរ ២១,៤-៩
ដំណឹងល្អ៖ យហ ៨,២១-៣០

បងប្អូនជាទីស្រឡាញ់!

អត្ថបទថ្ងៃនេះ ជួយឲ្យយើងគិតអំពីអត្ថន័យនៃអគ្គសញ្ញាលាបថ្ងាស នៅពេលព្រះយេស៊ូបានសន្ទនាជាមួយប្រជាជនយូដាជាច្រើន យើងបានស្តាប់ថា "**ពេលព្រះយេស៊ូមានព្រះបន្ទូលដូច្នេះ មានមនុស្សជាច្រើនបានជឿលើព្រះអង្គ**"។ គេជឿលើព្រះអង្គ ដោយសារគេបានស្តាប់ព្រះយេស៊ូ ព្រះអង្គបានបង្ហាញថាព្រះអង្គជាសេចក្តីពិតដែលព្រះជាម្ចាស់បានណែនាំឲ្យមក។ ពេលគេស្តាប់ព្រះយេស៊ូមានព្រះបន្ទូលអំពីផ្ទាល់ខ្លួន ណែនាំឲ្យគេយល់ថាព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ពិតមែន។ មានសំនួរមួយយ៉ាងសំខាន់ **តើលោកជានរណា?** យើងធ្លាប់គិតដែរនៅក្នុងជីវិតរបស់យើង តើព្រះយេស៊ូជានរណា? ព្រះយេស៊ូជាជីវិត ព្រះយេស៊ូជាសេចក្តីសង្ឃឹម។ ថ្ងៃនេះព្រះយេស៊ូបានប្រាប់អំពីព្រះអង្គផ្ទាល់ ថា **ខ្ញុំស្ថិតនៅ** (ព្រះយេស៊ូជាព្រះដែលមានព្រះជន្មគង់នៅ) ព្រះយេស៊ូជាជីវិតដែលស្ថិតនៅរហូត។ នៅក្នុងជីវិតរបស់យើងគ្រប់ពេលវេលា ដំណើរជីវិតរបស់យើងពិបាកឬស្រួល យើងដឹងថាព្រះយេស៊ូស្ថិតនៅ ព្រះយេស៊ូមិនដែលចោលយើង។ ពេលគេស្តាប់ដូចនេះ ណែនាំឲ្យគេសប្បាយចិត្ត ដោយសារជីវិតរបស់យើងត្រូវការកម្លាំង ពេលគេស្តាប់ថាព្រះយេស៊ូស្ថិតនៅ ព្រះយេស៊ូជាជីវិត ព្រះយេស៊ូមានព្រះជន្មគង់នៅជានិច្ច គេយល់ថានេះជាកម្លាំង។ ជីវិតរបស់យើងត្រូវការមានសេចក្តីសង្ឃឹមមកពីព្រះយេស៊ូ ថ្ងៃនេះខ្ញុំធ្វើអគ្គសញ្ញាលាបថ្ងាសដែលជាព្រះវិញ្ញាណដ៏វិសុទ្ធដែលយាងមក ដែលជាព្រះយេស៊ូផ្ទាល់ដែលយាងមកជាប់ជាមួយបងប្អូនថែមទៀត នេះជាសញ្ញាសម្គាល់អំពីព្រះយេស៊ូជាជីវិត អំពីព្រះយេស៊ូដែលជាសេចក្តីសង្ឃឹម អំពីព្រះយេស៊ូដែលណែនាំឲ្យជីវិតរបស់យើងលើផែនដីនេះ និងនៅស្ថានបរមសុខក៏មានតម្លៃដ៏ថ្លៃថ្នូរ ដោយសារយើងដឹងថាព្រះយេស៊ូឡើងទៅស្ថានបរមសុខដើម្បីទទួលស្វាគមន៍យើងទាំងអស់។ ជីវិតរបស់យើងដែលកំពុងធ្វើដំណើរក្នុងរដូវ៤០ថ្ងៃ យើងនឹកឃើញថា ធ្វើយ៉ាងដូចម្តេចដើម្បីជាប់ជាមួយព្រះយេស៊ូថែមទៀត? ធ្វើដូចម្តេចដើម្បីស្រឡាញ់បងប្អូនឯទៀតៗថែមទៀត? ដើម្បីជាប់ជាមួយព្រះយេស៊ូថែមទៀត យើង

ស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ អធិដ្ឋាន ចូលព្រះវិហារជារៀងរាល់ថ្ងៃ។ ដើម្បីជាប់ជាមួយបងប្អូនឯទៀតៗ យើងត្រូវបម្រើថែមទៀត ស្រឡាញ់ថែមទៀត។ យើងមានរដូវ៤០ថ្ងៃនេះដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូ ថ្ងៃនេះជាឱកាសពិសេសដោយសារជាទូទៅយើងមិនដែលធ្វើអគ្គសញ្ញាលាបថ្វាសក្នុងរដូវ៤០ថ្ងៃ ប៉ុន្តែជាសញ្ញាមួយពិតមែនព្រះយេស៊ូជាជីវិត។ នៅពេលព្រះយេស៊ូសោយទិវង្គតហើយ យើងគោរពព្រះយេស៊ូដែលមានជីវិតអស់កាលជានិច្ច។ ពេលខ្ញុំឲ្យព្រះវិញ្ញាណដ៏វិសុទ្ធ ខ្ញុំជឿថានេះជាជីវិតរបស់ព្រះយេស៊ូ ដូចយើងបានស្តាប់ **ខ្ញុំស្ថិតនៅ** ព្រះវិញ្ញាណដ៏វិសុទ្ធដែលខ្ញុំបានឲ្យថ្ងៃនេះជាសញ្ញាសម្គាល់ជាក់ស្តែង ពិតមែនព្រះយេស៊ូស្ថិតនៅ។ នេះជាកម្លាំងមួយសម្រាប់បងប្អូន ជាសេចក្តីសង្ឃឹមដែលយើងមាននៅក្នុងជីវិតរបស់យើង ដោយដឹងថាព្រះយេស៊ូមិនដែលលះបង់ចោលយើង ព្រះយេស៊ូធ្វើដំណើរជាមួយយើង និងព្រះយេស៊ូបន្តចាប់ដៃយើងដើម្បីធ្វើដំណើរតទៅទៀត។

ថ្ងៃនេះសូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គគង់នៅជាមួយយើងថែមទៀត ដើម្បីឲ្យយើងមានសេចក្តីសង្ឃឹមជានិច្ច ដើម្បីឲ្យមានកម្លាំងកាយកម្លាំងចិត្ត ដោយដឹងថាពិតមែនព្រះយេស៊ូស្ថិតនៅ ព្រះយេស៊ូមានព្រះជន្មគង់នៅជាមួយយើងជារៀងរហូត។ អាម៉ែន។